# បុណ្យសែនក្បាលទឹក

បុណ្យសែនក្បាលទឹក ជាទំនៀមមួយរបស់ជនជាតិចិន និងវៀតណាម ប៉ុន្តែមានប្រទេសជាច្រើនណាស់នៅអាស៊ីដែលប្រារព្ធពិធីនេះ ដោយសារតែមានវត្តមានរបស់ប្រជាជនចិន វៀតណាម ឬប្រជាជនដែលជាប់សាច់ឈាមនឹងជនជាតិទាំងពីរនេះ។ បុណ្យសែនក្បាលទឹក ជាឈ្មោះពិធីបុណ្យ ដែលប្រជាជនខ្មែរហៅសម្គាល់ពិធីបុណ្យសែនឱ្យខ្មោច (ខ្មោចដែលអត់ឃ្លាន) ដែលមានអត្ថន័យស្រដៀងនឹងពិធីបុណ្យភ្ជុំបិណ្ឌរបស់ខ្មែរ។[១] ពិធីបុណ្យនេះប្រារព្ធធ្វើឡើងនៅថ្ងៃទី១៥កើត ខែទី៧ របស់ច័ន្ទគតិ ដែលស្ថិតនៅក្នុងខែសីហា ក្នុងប្រតិទិនសុរិយគតិ។ ក្នុងថ្ងៃនេះប្រជាជនចិន វៀតណាម និងអ្នកជាប់ខ្សែលោហិតចិនធ្វើការគោរពដូនតា ហើយក៏រៀបចំគ្រឿងសំណែនជាច្រើនថ្វាយចំពោះព្រលឹងដែលវង្វេងនៅលើផែនដីនេះ[២] (រូបលេខ១)។

សារៈសំខាន់របស់ពិធីបុណ្យសែនខ្មោច ឬសែនក្បាលទឹកនេះ មានភាពខុសប្លែកគ្នារវាងបុណ្យរបស់ពួកអ្នកកាន់សាសនាតាវ និងព្រះពុទ្ធសាសនា។ ជំនឿរបស់ពួកតាវច្រើនតែទាក់ទងដល់ការធ្វើឱ្យព្រលឹងឃ្លាតចេញពីភពនេះទៅ។ ចំណែកឯខាងព្រះពុទ្ធសាសនាទាក់ទងនឹងការគោរពបូជាព្រលឹងទៅវិញ។[៣] យោងទៅលើប្រពៃណីពួកអ្នកកាន់សាសនាតាវយល់ថា វាសនារបស់មនុស្សគ្រប់គ្រងដោយទេពបីអង្គ ទី១ គាន់ដាឌី (Guan Da Di) ដែលជាទេពគ្រប់គ្រងនៅស្ថានសួគ៌ និងជាអ្នកផ្តល់នូវសុភមង្គល ទី២ ឌីគាន់ដាឌី (Di Guan Da Di) ជាទេពគ្រប់គ្រងផែនដី ហើយដែលជួយលើកលែងទោសកំហុសឬបាបកម្ម ទី៣ សួយគាន់ដាឌី (Shui Guan Da Di) ជាទេពគ្រប់គ្រងទឹក និងជួយការពារកាត់បន្ថយគ្រោះអាសន្ន។ ដូច្នេះថ្ងៃសែនក្បាលទឹក ដែលជាថ្ងៃទី១៥ ត្រូវនឹងខែស្រាពណ៍ នេះ គឺចំនឹងថ្ងៃកំណើតរបស់ទេព ឌីគាន់ដាឌី (Di Guan Da Di) ដែលបានចុះមកផែនដី ដើម្បីកត់ត្រានូវកម្មរបស់មនុស្ស។[៤] អំឡុងខែស្រាពណ៍នេះ គេជឿថាច្រកនរកនឹងបើកចំហរ ហើយ

---

[១] Ghost Festival, wikieda.org

[២] Sim Cheryl. 2004

[៣] Ibit

[៤] Hungry Ghosts Festival, Brill.2018

អត្ថបទដោយ៖ មាស សុភាព

ព្រលឹងខ្មោចដែលមានភាពអត់ឃ្លានទាំងនោះ នឹងត្រូវបានដោះលែងពីនរក ឬកពវង្វេងខាងក្រោមមកកាន់ផែនដីរបស់មនុស្ស ដើម្បីរកអាហារ[៥](រូបលេខ២)។ តាមទំនៀមរបស់ពួកតាវ គឺអាចារ្យនឹងរៀបចំពិធី ហើយសែនអាហារ ចំណែកពួកសាសនិកនឹងបន់ស្រន់សុំខមាទោសកំហុស ព្រមទាំងបួងសួងសុំសេចក្តីសុខបញ្ចៀសគ្រោះថ្នាក់ជាអាទិ៍។ ដោយឡែកចំពោះពុទ្ធសាសនិកវិញ ការធ្វើបុណ្យសែនព្រេនអាហារទាំងឡាយនេះ គឺដើម្បីជួយសង្គ្រោះដូនតារបស់ខ្លួនដែលបានរំលាយក្ខន្ធទៅ ហើយធ្លាក់ខ្លួនរងទុក្ខវេទនាព្រោះតែអត់អាហារ។

ពិធីបុណ្យនេះ មានប្រភពមកពីឥណ្ឌាបុរាណ។ ពិធីបុណ្យនេះ មានចែងក្នុងគម្ពីរព្រះពុទ្ធសាសនាមហាយាន ឈ្មោះថា Ullabana Sutra។ សម្រាប់ពិធីបុណ្យបែបព្រះពុទ្ធសាសនាថេរវាទ គឺជាទម្រង់ពិធីបុណ្យរបស់អ្នកស្រុកឥណ្ឌាខាងត្បូង និងអាស៊ីអាគ្នេយ៍។ វាមានប្រភពពីគម្ពីរបាលី ឈ្មោះថា Petavatthu និងមានអាយុកាល ប្រហែលសតវត្សទី៣មុនគ្រិស្តសករាជ។ បើយោងតាមបែបបាលី តួអង្គក្នុងសាច់រឿងនេះ គឺ ព្រះសារីបុត្រ ច្រើនជាងព្រះមោគ្គលាន។[៦] បើរឿងតាមបែបជនជាតិចិនវិញ បុណ្យនេះកើតឡើងដោយសារទង្វើរបស់ **ម៉ូលៀន (មោគ្គលាន)** ដែលជាកូនសិស្សរបស់ព្រះសម្មាសម្ពុទ្ធក្នុងការជួយសង្គ្រោះព្រលឹងម្តាយដែលបានស្លាប់ទៅ ហើយទទួលរងទណ្ឌកម្មនៅស្ថាននរក ក៏ព្រោះតែគាត់បានបរិភោគសម្ងសាច់ដោយអចេតនា។ **ម៉ូលៀន** បានព្យាយាមស្វែងរកម្តាយគាត់គ្រប់ទីស្ថាន ហើយចុងក្រោយបានរកឃើញនៅក្នុងចំណោមខ្មោចដែលអត់ឃ្លាន (រូបលេខ៣)។ ទោះបីជា ម៉ូលៀន ខំចិញ្ចឹមផ្តល់អាហារយ៉ាងណាក៏គាត់មិនអាចទទួលអាហារនោះបាន ប៉ុន្តែបែរជាខ្មោចផ្សេងទទួលបានទៅវិញ។ នៅក្នុងអត្ថបទខ្លះនិយាយថា កូនបានផ្ញើបាយទៅឱ្យម្តាយ ប៉ុន្តែបាយនោះមានក្លាយជាធ្យូង ហើយឆេះមុនពេលដែលដាក់ចូលក្នុងមាត់របស់គាត់។ ដូច្នេះក្រោយពីទទួលបានការប្រៀនប្រដៅពីព្រះពុទ្ធ ម៉ូលៀន បានធ្វើទានអាហារ និងអធិស្ឋានបួងសួងបញ្ជូនទៅឱ្យម្តាយ ទើបម្តាយគាត់បានធូរស្បើយពីការឈឺចាប់ដោយអត់ឃ្លាន។ ជំនឿ បែបជួយសង្គ្រោះព្រលឹងនេះ មិនខុសប្លែកអ្វីពីការបួសមុខភ្លើង

---

[៥] Chinese Ghost Festival: ZhongYuan Festival, Chinese.com

[៦] Ghost Festival, wikieda.org

អត្ថបទដោយ៖ មាស សុភាព

នោះទេ (រូបលេខ២)។ ចំណែករឿងមួយទៀត គឺទាក់ទងនឹងស្តេចនាគ សមុទ្រខាងកើត ដែលមានចិត្តច្រណែន ហើយតាំងគម្រោងបង្ខូចគ្រូទាយ។ ក្រោយមកគាត់ត្រូវកាត់ទោសប្រហារជីវិត។ គ្រានោះគាត់មានសុំជំនួយពីព្រះចៅអធិរាជថាង ហើយដោយការអាណិតអាសូរ ទ្រង់បានសន្យានឹងជួយសង្គ្រោះស្តេចនាគ។ ជាអកុសលព្រះអង្គមិនអាចជួយស្តេចនាគបាន ធ្វើឱ្យស្តេចនាគខឹងព្រោះតែព្រលឹងរបស់ខ្លួនបានវង្វេង (រូបលេខ៥)។ លុះដល់ថ្ងៃ១៥កើត ខែស្រាពណ៍នេះ ទើបព្រះមហាក្សត្រធ្វើបុណ្យឧទ្ទិសអាហារ និងភេសជ្ជៈដល់ស្តេចនាគ។[៧] គួរបញ្ជាក់ផងដែរថា ពិធីបុណ្យនេះបានប្រារព្ធខុសប្លែកគ្នាខ្លះដែរ។ ពួកជនជាតិចិន ច្រើនធ្វើម្ហូបអាហារ ដុតទៀនធូប ក្រដាសប្រាក់ របស់ប្រើប្រាស់ សំលៀកបំពាក់ជាដើមដល់អ្នកស្លាប់។

ក្នុងរវៀងថ្ងៃនៃពិធីបុណ្យនេះក៏មានត្រណមផងដែរ។ ក្នុងនោះគេជៀសវាងកុំឱ្យដើរជាន់ ឬទាត់តង្វាយដែលគេបានគេបានដាក់សែន ទោះជានៅតាមចិញ្ចើមថ្នល់ក្តី ព្រោះនឹងធ្វើឱ្យខ្មោចខឹង។ ម្យ៉ាងទៀត គេហាមប្រាមមិនឱ្យពាក់អាវពណ៌ក្រហមនោះទេ ពីព្រោះគេជឿថាពណ៌នេះនឹងអាចទាក់ទាញព្រលឹងខ្មោច។ ចំពោះគ្រឿងស្រវឹងក៏ត្រូវជៀសវាងដាច់ខាត ពីព្រោះវាអាចឱ្យខ្មោចចូលកាន់ខ្លួនបានដោយងាយស្រួល។ លើសពីនេះ ការកោរសក់ និងព្យួរសំលៀកបំពាក់នៅខាងក្រៅផ្ទះពេលយប់ ព្រមទាំងផ្លាស់ប្តូរផ្ទះ ឬទិញទំនិញនឹងត្រូវគេហាមផងដែរ។

សរុបមក ពិធីបុណ្យសែនក្បាលទឹក ជាឈ្មោះពិធីបុណ្យដែលខ្មែរបានហៅ សំដៅដល់ពិធីបុណ្យសែនព្រេនទៅដល់ព្រលឹងអ្នកស្លាប់ដែលអត់ឃ្លាន។ ហើយការហៅឈ្មោះបែបនេះ ប្រហែលជាអាចទាក់ទងនឹងសាច់រឿងរបស់ស្តេចនាគសមុទ្រខាងកើត ច្រើនជាងទាក់ទងនឹងការសង្គ្រោះព្រលឹងម្តាយ ដោយយោងទៅលើសមុទ្រ ឬទឹក។ ពិធីបុណ្យនេះមានឫសគល់ពីគម្ពីរបុរាណរបស់តណ្ហា ទាំងតាមបែបព្រះពុទ្ធសាសនាថេរវាទ និងព្រះពុទ្ធសាសនាមហាយាន។ ការប្រតិបត្តិពិធីបុណ្យសែនព្រេនទៅដល់ខ្មោចអត់ឃ្លាន គឺមានលក្ខណៈស្រដៀងគ្នាណាស់ ចំពោះប្រទេសនៅអាស៊ីទាំងមូល ឬប្រទេសដែលកាន់ព្រះពុទ្ធសាសនា។

---

[៧] Sim Cheryl. 2004

អត្ថបទដោយ៖ មាស សុភាព

# បញ្ជីរូបភាព



រូបលេខ១ គ្រឿងសំណែនដល់ព្រលឹងដូនតា ឬអ្នកស្លាប់។



រូបលេខ២ ការរៀបចំចាត់ចែងព្រលឹងនៅស្ថាននរក



រូបលេខ៣ រូបតំណាង ព្រះពុទ្ធ ឬព្រះមោគ្គលាន ឬព្រះសារីបុត្រនៅស្ថាននរក

អត្ថបទដោយ៖ មាស សុភាព



រូបលេខ២៨ ការបួសមុខភ្លើង សង្គ្រោះព្រលឹងអ្នកស្លាប់



រូបលេខ២៩ ព្រះលោកេស្វរ ដឹកនាំព្រលឹង និងសង្គ្រោះព្រលឹងអ្នកស្លាប់

អត្ថបទដោយ៖ មាស សុភាព

# ឯកសារពិគ្រោះ

Sim Cheryl

2004. “Zhong Yuan Jie (Hungry Ghost Festival)”.
*https://eresources.nlb.gov.sg/infopedia/articles/SIP_758_2004-12-16.html*

www.wikipedia.org. “The Ghost Festival”.
www.chinesehsk.com. “Chinese Ghost Festival: Zhong Yuan Festival”.
https://brill.com. “Hungry Ghosts Festival”.